ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តក្រចេះ
លេខ: ០២៦ ស.ស.រ
១៧

# សេចក្តីសម្រេច
# ស្តីពី
# ការមិនអនុញ្ញាតឲ្យអ្នកទទួលការដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់

## អភិបាលខេត្តក្រចេះ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រឹត្យលេខនស/រកម/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលបានប្រកាសអោយ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៥១៦/៥៦៦ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការតែងតាំងអភិបាល នៃគណៈអភិបាលខេត្តក្រចេះ
- បានឃើញអនុក្រឹត្យលេខលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទីភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងសេចក្តីសម្រេចលេខ០០១ស.ស.រ/គ.ជ.វ.រ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៩ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការស្តីពីការដាក់ឲ្យប្រើប្រាស់សៀវភៅណែនាំ ស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ ដែលត្រូវបានកែសម្រួលលើកទី២
- លិខិតលេខ៣៩២/១៧ឃគល ចុះថ្ងៃទី២/៥/២០១៧ របស់ឃុំគោលាប់ស្តីពីសំណើសុំដកសិទ្ធិអ្នកទទួលការឈ្មោះហួត ឡូត ក្រុមហ៊ុនអៀងសុខអេង មិនអនុញ្ញាតឲ្យចូលដេញថ្លៃគម្រោងមូលនិធិឃុំ ខេត្តក្រចេះ

- លិខិតលេខ០៣១/១៧លស ចុះថ្ងៃទី១៧/៥/២០១៧របស់ឃុំឃ្សឹម ស្តីពីសំណើសុំដកសិទ្ធិអ្នកទទួលការឈ្មោះ ហួត ឡូត ក្រុមហ៊ុន អៀងសុខអេង មិនអនុញ្ញាតឲ្យចូលដេញថ្លៃគម្រោងមូលនិធិឃុំសង្កាត់ខេត្តក្រចេះ
- លិខិតលេខ១៥៤/១៧ឃ.ស.ជ ចុះថ្ងៃទី១៧/៥/២០១៧របស់ឃុំស្រែជិះស្តីពីសំណើសុំដកសិទ្ធិក្រុមហ៊ុនអៀងសុខអេងដែលមានប្រធានក្រុមហ៊ុនឈ្មោះ ហួត ឡូត មិនអនុញ្ញាតឲ្យចូលដេញថ្លៃគម្រោងមូលនិធិឃុំ ខេត្តក្រចេះ

## សម្រេច

**ប្រការ ១៖** មិនអនុញ្ញាតឲ្យក្រុមហ៊ុន **អៀងសុខអេង** ប្រធានក្រុមហ៊ុនឈ្មោះ **ហួត ឡូត** ដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៦លេខរៀងទី១០ នៅខេត្តស្ទឹងត្រែង ចូលដេញថ្លៃគម្រោងមូលនិធិឃុំ/សង្កាត់ ក្នុងខេត្តក្រចេះ មូលហេតុដោយក្រុមហ៊ុននេះមិនអនុវត្តកិច្ចសន្យាក្នុងការអនុវត្តគម្រោងមូលនិធិឃុំឆ្នាំ២០១៦របស់ឃុំគោលាប់ ស្រុកចិត្របុរី ឃុំឃ្សឹម ស្រុកស្នួល ឃុំស្រែជិះ ស្រុកសំបូរ ខេត្តក្រចេះ ។

**ប្រការ២៖** ក្រុមហ៊ុន **អៀងសុខអេង** ប្រធានក្រុមហ៊ុនឈ្មោះ **ហួត ឡូត** មិនមានសិទ្ធិចូលរួមដេញថ្លៃគម្រោងមូលនិធិឃុំ/សង្កាត់ដោយផ្ទាល់ ឬ ដោយប្រយោល ឬ ជាតំណាងឲ្យក្រុមហ៊ុនផ្សេងទៀតបានឡើយ(រយៈពេលចំនួនប្រាំឆ្នាំគិតពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៧ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២១)។

**ប្រការ៣៖** នាយករដ្ឋបាលសាលាខេត្ត នាយកទីចាត់ការទាំង៥ និង ប្រធានអង្គភាពលទ្ធកម្មចំណុះរដ្ឋបាលខេត្ត រដ្ឋបាលក្រុង/ស្រុក សាលាឃុំ/សង្កាត់ទូទាំងខេត្ត និងក្រុមហ៊ុន **អៀងសុខអេង** ប្រធានក្រុមហ៊ុនឈ្មោះ **ហួត ឡូត** ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ក្រចេះ.ថ្ងៃទី២៨ ខែឧសភា ឆ្នាំ ២០១៧

**អ ភិ បា ល ខេ ត្ត**

**សរ ចំរុង**

<u>ចម្លងជូន</u>
-លេខាធិការដ្ឋាន គ ជ អ ប
-ឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត
-រតនាគារខេត្ត
"ដើម្បីជូនជ្រាប"
-ដូចប្រការ៣
"ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ